ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

Ministry of Industry & Handicraft

លេខ: ១៤០ MIH / 2016

# ប្រកាស

## ស្តីពី

## បទប្បញ្ញត្តិបច្ចេកទេស

## សម្រាប់ផលិតផលយានយន្ត ចំនួន ១៩

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីស្តង់ដារកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញប្រកាសលេខ ១៤១ MIH/2014 ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាស្តង់ដារជាតិ
- យោងរបាយការណ៍នៃកិច្ចប្រជុំលើកទី១៥ របស់ក្រុមប្រឹក្សាស្តង់ដារជាតិ នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៥

## សម្រេច

**ប្រការ១** ៖ កំណត់បទប្បញ្ញត្តិបច្ចេកទេសចំនួន ១៩ សម្រាប់ផលិតផលយានយន្ត ដែលបានធ្វើសុខដុមនីយកម្មក្នុងអាស៊ាន ដោយយកតាមបទប្បញ្ញត្តិបច្ចេកទេសរបស់សហគមន៍សេដ្ឋកិច្ចអឺរ៉ុប (UNECE Regulation) ទាំងស្រុង ក្នុងគោលបំណងធ្វើឲ្យផលិតផលយានយន្តមានសុវត្ថិភាព និងបង្កាភាពមហន្តរាយដែលប៉ះពាល់ដល់មនុស្ស បរិស្ថាន និងសង្គម ដែលមានដូចខាងក្រោម៖



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៩៤
អ៊ីមែល: mih.smcabinet@gmail.com

| ល.រ | លេខបទប្បញ្ញត្តិបច្ចេកទេស *CTR Number* | លេខស្តង់ដារកម្ពុជា *CS Number* | ចំនងជើងស្តង់ដារ | លេខកូដ *UNECE Regulations* |
|---|---|---|---|---|
| 1 | CTR 130:2016 | CS 523:2016 (UNR13) | ប្រព័ន្ធហ្វ្រាំង | R13 |
| 2 | CTR 131:2016 | CS 524:2016 (UNR13H) | ប្រព័ន្ធហ្វ្រាំងរថយន្តទេសចរណ៍ | R13H |
| 3 | CTR 132:2016 | CS 525:2016 (UNR14) | បង្គោលភ្ជាប់ខ្សែក្រវ៉ាត់សុវត្ថិភាព | R14 |
| 4 | CTR 133:2016 | CS 526:2016 (UNR16) | ខ្សែក្រវ៉ាត់សុវត្ថិភាព | R16 |
| 5 | CTR 134:2016 | CS 527:2016 (UNR17) | កៅអី | R17 |
| 6 | CTR 135:2016 | CS 528:2016 (UNR25) | ក្បាលកៅអី | R25 |
| 7 | CTR 136:2016 | CS 529:2016 (UNR30) | កង់រថយន្ត - រថយន្តទេសចរ | R30 |
| 8 | CTR 137:2016 | CS 530:2016 (UNR39) | កុងទ័រល្បឿន | R39 |
| 9 | CTR 138:2016 | CS 531:2016 (UNR40) | ការបំភាយផ្សែង សម្រាប់ម៉ូតូ | R40 |
| 10 | CTR 139:2016 | CS 532:2016 (UNR41) | សំលេង សម្រាប់ម៉ូតូ | R41 |
| 11 | CTR 140:2016 | CS 533:2016 (UNR43) | កញ្ចក់សុវត្ថិភាព | R43 |
| 12 | CTR 141:2016 | CS 534:2016 (UNR46) | កញ្ចក់មើលក្រោយ | R46 |
| 13 | CTR 142:2016 | CS 535:2016 (UNR49) | ការបំភាយផ្សែងម៉ាស៊ីត | R49 |
| 14 | CTR 143:2016 | CS 536:2016 (UNR51) | ការបញ្ចេញសំលេង | R51 |
| 15 | CTR 144:2016 | CS 537:2016 (UNR54) | កង់រថយន្ត - ដឹកទំនិញ | R54 |
| 16 | CTR 145:2016 | CS 538:2016 (UNR60) | ផ្ទាំងត្រួតពិនិត្យការបើកបរ | R60 |
| 17 | CTR 146:2016 | CS 539:2016 (UNR75) | សំបកកង់ម៉ូតូ | R75 |
| 18 | CTR 147:2016 | C79S 540:2016 (UNR79) | សំភារៈដៃចង្កូត | R79 |
| 19 | CTR 148:2016 | CS 541:2016 (UNR83) | ការបំភាយផ្សែងសម្រាប់រថយន្តធុនស្រាល | R83 |

**ប្រការ២** ៖ បុគ្គលណាមួយដែលផលិត កែច្នៃ នាំចូល ផ្សព្វផ្សាយពាណិជ្ជកម្មលក់ ឬ លក់ផលិតផលយានយន្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសដូចមានចែងក្នុងប្រការ ១ ខាងលើជាដាច់ខាត និងត្រូវមានអាជ្ញាប័ណ្ណ និងមានបិទសញ្ញាស្តង់ដារកម្ពុជា "**សុវត្ថិភាព**" នៅលើយានយន្តនោះ។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៥៤
អ៊ីម៉ែល: mih.smcabinet@gmail.com

**ប្រការ៣ ៖** ក្នុងករណីផលិតផលយានយន្ត មិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសដូចមានចែងក្នុងប្រការ ១ ខាងលើ រូបវន្តបុគ្គល ឬនីតិបុគ្គលដែលផលិត កែច្នៃ នាំចូល ផ្សព្វផ្សាយពាណិជ្ជកម្មលក់ ឬ លក់ផលិតផលយានយន្តនោះ ត្រូវផ្តន្ទាទោសតាមច្បាប់ស្តីពីស្តង់ដារកម្ពុជា។

**ប្រការ៤ ៖** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៥ ៖** នាយកខុទ្ទកាល័យ អគ្គនាយក ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល អគ្គាធិការ ប្រធាននាយកដ្ឋានបញ្ញត្តកម្ម ប្រធាននាយកដ្ឋាននីតិកម្ម ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី-ខេត្ត និងអង្គភាពក្រោមឱវាទក្រសួង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

**ប្រការ៦ ៖** ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តបន្ទាប់ពីរយៈពេល ៦០ថ្ងៃ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល ៖**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័នដែលមានតំណាងជាសមាជិកក្រុមប្រឹក្សាស្តង់ដារជាតិ
- គ្រប់អគ្គនាយកដ្ឋានចំណុះក្រសួង
- គ្រប់មន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី-ខេត្ត
- ឯកសារ-កាលប្បវត្តិ



ក្រសួងឧស្សាហកម្មនិងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៩៤
អ៊ីម៉ែល: mih.smcabinet@gmail.com